

ប្រទេសកម្ពុជា

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែកក្កដា ឆ្នាំ២០២២

ផ្ដោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលលោក លើ តម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ


កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បុព្វកថា

**ជិតកន្លះឆ្នាំក្នុងជម្លោះអ៊ុយក្រែន** សង្គ្រាម និងការដាក់ទណ្ឌកម្មលើរុស្ស៊ី កំពុងធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យ៉ូម អាសូត ផូស្វ័រ)។ ប្រទេសរុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។

**ជម្លោះនេះបានផ្លាស់ប្តូរគំរូពាណិជ្ជកម្ម ផលិតកម្ម និងការប្រើប្រាស់ជាសកល**ឲ្យទៅជាឥទ្ធិពល ដែលតម្លៃនឹងស្ថិតក្នុងកម្រិតខ្ពស់ជាប្រវត្តិសាស្ត្រ រហូតដល់ចុងឆ្នាំ២០២៤ ធ្វើឲ្យអសន្តិសុខស្បៀង និងអតិផរណាស្បៀងអាហារកាន់តែធ្ងន់ធ្ងរ។ ទោះជាមានភាពល្អប្រសើរខ្លះៗក៏ដោយ ក៏អតិផរណាក្នុងប្រទេសជុំវិញពិភពលោកនៅតែខ្ពស់ក្នុងខែកក្កដា។

**លទ្ធភាពទទួលបានជីនឹងក្លាយជាបញ្ហាប្រឈមចម្បងនៅប៉ុន្មានខែខាងមុខ** ដោយសារជីសកលនៅតែមានតម្លៃខ្ពស់។ នេះទំនងជាមានឥទ្ធិពលខ្លាំងដល់ផលិតកម្មស្បៀងអាហារនៅជុំវិញពិភពលោកក្នុងឆ្នាំ២០២៣។ ការគំរាមកំហែង ដែលបង្កឡើងដោយអាកាសធាតុ ទំនងជាធ្វើឲ្យទិន្នផលស្បៀងអាហារសកលកាន់តែថយចុះថែមទៀត។ ដើម្បីការពារខ្លួនពីឥទ្ធិពលអាក្រក់ និងធានានូវសុវត្ថិភាពស្បៀង ប្រទេសចំនួន២៥ បានជំរុញការរឹតបន្តឹងការនាំចេញស្បៀងអាហារ គិតត្រឹមខែកក្កដា ឆ្នាំ២០២២។ គួរកត់សម្គាល់ថា កប៉ាល់ទី១ដែលដឹកធញ្ញជាតិរបស់អ៊ុយក្រែនបានចាក់ចេញពីកំពង់ផែអូដេសានៅថ្ងៃទី១ ខែសីហា បន្ទាប់ពីរុស្ស៊ីបានដកការទប់ស្កាត់រយៈពេល១ខែមក។

**ជម្លោះនេះត្រូវបានព្យាករថានឹងប៉ះពាល់យ៉ាងខ្លាំងដល់មនុស្ស ១,៧ ពាន់លាននាក់ ក្នុង ១០៧ ប្រទេស** ជាមួយនឹងការកើនឡើងចំនួនមនុស្ស ដែលមានអសន្តិសុខស្បៀងធ្ងន់ធ្ងរដល់ ៣៤៥ លាន នាក់ ត្រឹមខែមិថុនា ឆ្នាំ២០២២។ ជារួម មនុស្សប្រមាណ ៦៧០ លាននាក់ នឹងនៅតែស្រេកឃ្លាននៅឆ្នាំ២០៣០ ស្មើនឹងស្ថានភាពមូលដ្ឋានក្នុងឆ្នាំ២០១៥ និងឆ្ងាយពីគោលដៅដែលកំណត់ដោយ SDGs។

**នេះមិនបានកើតឡើងដាច់ដោយឡែកទេ។** ចាប់តាំងពីដើមឆ្នាំ២០២០ មក កូវីដ-១៩បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារជាហេតុធ្វើឲ្យកើនឡើងអតិផរណា នឹងបំណុលក្នុងប្រទេសជាច្រើន - ធ្វើឲ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។

**ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កម្ពុជាជាប្រទេសប្រឈមខ្លាំងទៅនឹងការកើនឡើងតម្លៃថាមពល** ដោយសារតែការនាំចូលឥន្ធនៈខ្ពស់ធៀបនឹង GDP ការប្រើប្រាស់អគ្គិសនីក្នុងស្រុកនៅមានកម្រិត និងការពឹងលើឥន្ធនៈផូស៊ីល។ ជាការពិត ការឡើងថ្លៃប្រេងគួបផ្សំនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងចិន ដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់កម្ពុជា ជាកត្តាសំខាន់រារាំងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលបានព្យាករនៅត្រឹម ៤,៥% សម្រាប់ឆ្នាំ២០២២។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានា ក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ (ឧបសម្ព័ន្ធទី១ និងទី២) នៅក្នុងផ្សារចំនួន ៤៥ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្ត្រ)។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ២៥០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។

# មាតិកា


១. **របកគំហើញសំខាន់ៗ** ៣

២. **លទ្ធផល**

ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ ៤

ការទៅផ្សារ៖ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន ៨

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ៩

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ នឹងទីប្រជុំជន ១០

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១១

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១២

៣. **បរិបទ**

ពាណិជ្ជកម្ម ១៣

ការឆ្លើយតបផ្នែកនយោបាយ ១៤

៤. **វិធីសាស្ត្រ និងទីតាំងផ្សារ** ១៥

៥. **ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៦

៦. **ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៧

៧. **ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

## កូវីដ-១៩ និងកត្តាបរិស្ថាន ដែលមានឥទ្ធិពលលើតម្លៃ

**GDP**

២០២១ ៣,០%

២០២២ ៤,៥%

**អតិផរណា**

CPI ឧសភា ២០២២ ២០០,៤

CPI មិថុនា ២០២២ ២០២,១ (+០,៨% MoM, +៧,៨% YoY)

*ADB ព្យាករអត្រាអតិផរណានៅកម្ពុជាថាកើនដល់ ៤,៧% នៅឆ្នាំ២០២២។ ក្នុងខែមិថុនា ឆ្នាំ២០២២ សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ (CPI)* របស់វិទ្យាស្ថានជាតិស្ថិតិបានកើនឡើង ០,៨% ធៀបនឹងខែមុន (MoM) និង ៧,៨% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ សន្ទស្សន៍តម្លៃស្បៀងអាហារ (FPI) របស់ CPI បានកើនឡើង ០,៧% MoM និង ៦,៦% (YoY)។ គ្រួសារកម្ពុជាចំណាយស្មើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ (៦០% សម្រាប់គ្រួសារក្រីក្រ) (CSES ២០១៩/២០)។*

**CPI ក្នុងខែកក្កដា ឆ្នាំ២០២២ មិនទាន់មាននៅឡើយទេ កំឡុងពេលរៀបចំរបាយការណ៍*




*សន្ទស្សន៍នៃតម្លៃស្បៀងអាហារសកលរបស់ FAO (FFPI) ក្នុងខែកក្កដា ឆ្នាំ២០២២ នៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១៣,១% បើទោះជាវាបានធ្លាក់ចុះបន្តិចធៀបនឹងខែមុន (-៨,៧%) ដោយសារតម្លៃធញ្ញជាតិ និងប្រេងឆាក្នុងសកលលោកនៅតែខ្ពស់។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា




*ការកើនឡើងនៃតម្លៃប្រេងឥន្ធនៈលើសកលលោកបានធ្វើឲ្យតម្លៃលក់រាយប្រេងសាំង (ធម្មតា) នៅកម្ពុជាហក់ឡើង ៣០,០% និងប្រេងម៉ាស៊ូតហក់ឡើង ៥៧,០% បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន បើទោះជាតម្លៃធ្លាក់ចុះ ៨,០% សម្រាប់ប្រេងសាំង (ធម្មតា) និង ៥,០% សម្រាប់ប្រេងម៉ាស៊ូត បើធៀបនឹងខែមុន។ បញ្ហានេះនៅតែមានឥទ្ធិពលអវិជ្ជមានលើផលិតកម្មស្បៀង ព្រោះតម្លៃនៅតែខ្ពស់ ហើយកសិដ្ឋានជាទូទៅដំណើរការដោយប្រើប្រេងឥន្ធនៈ។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា
២០២២

# សង្ខេបរបកគំហើញសំខាន់ៗ

តម្លៃស្បៀងអាហារនៅកម្ពុជានៅមានស្ថេរភាព តែឡើងខ្ពស់ក្នុងខែកក្កដា។ តម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋានបានកើនឡើងបន្តិច ដល់ ១០៦.៦២៥ រៀល/ម្នាក់/ខែ (+០,៥% ធៀបនឹងខែមុន -០,២% ធៀបនឹងឆ្នាំមុន) ស្មើនឹង ២៦,០ ដុល្លារ។ ជារួម តម្លៃនៅជនបទបានថយចុះបន្តិច (-០,៣% ធៀបខនឹងខែមុន) តែបានកើនឡើងនៅទីប្រជុំជន (+០,៩% ធៀបនឹងខែមុន)។

ចន្លោះខែមិថុនា និងខែកក្កដា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយសម្រាប់ស្បៀងអាហារសំខាន់ៗភាគច្រើនបានប្រែប្រួលតិចតួចប៉ុណ្ណោះ (±≤៥,០%)។ បម្រែបម្រួលតម្លៃស្បៀងភាគច្រើនមាននៅជនបទ។ ស្បៀងអាហារមួយចំនួននៅក្នុងកញ្ចប់ស្បៀងអាហារបង្ហាញនិន្នាការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងរយៈពេលវែង រួមមាន ប្រេងឆា (+៣១,៥% ធៀបឆ្នាំមុន) ដែលភាគច្រើននាំចូល ស៊ុតទា (+១៩,៦% ធៀបឆ្នាំមុន) និងត្រកួន (+១០,៧% ធៀបឆ្នាំមុន)។

ផ្សារមានដំណើរការមិនល្អទេក្នុងខែកក្កដា ដោយសន្ទស្សន៍ដំណើរការរបស់ផ្សារ (MFI) បានធ្លាក់ចុះទាបខ្លាំងបំផុតក្នុងឆ្នាំ២០២២។ នេះដោយសារតែការធ្លាក់ចុះខ្លាំងនូវភាពអាចរកបានជាក់ស្តែងនៃទំនិញនៅលើទីផ្សារ និងតម្លៃទីផ្សារដែលអាចព្យាករបាន។ ជាមួយគ្នាដែរ ចំនួនអតិថិជនទៅផ្សារក៏បានធ្លាក់ដល់កម្រិតទាបម្តងទៀតក្នុងឆ្នាំ២០២២។ សរុបមក ការរកឃើញនេះបង្ហាញថាមានការធ្លាក់ចុះនូវតម្រូវការអតិថិជន។

ដោយសារប្រេងឥន្ធនៈ និងជីកសិកម្មនៅតែមានតម្លៃខ្ពស់ តម្លៃស្បៀងអាហារទំនងជានៅតែខ្ពស់ក្នុងរយៈពេលខ្លី។ ការចំណាយលើការរស់នៅនៅកម្ពុជាកំពុងជួបបញ្ហា ដែលធ្វើឲ្យអំណាចទិញរបស់គ្រួសារត្រូវបានកាត់បន្ថយ ដូចបានបង្ហាញពីការធ្លាក់ចុះនូវតម្រូវការអតិថិជន។ គ្រួសារក្រីក្រនឹងជួបបញ្ហាលទ្ធភាពទិញ ដោយសារពួកគេបានចំណាយប្រាក់ចំណូលភាគច្រើន (៦០%) ទោះជាក្នុងស្ថានភាពធម្មតា (CSES ២០១៩/២០)។

# ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថិរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ផ្សារមានដំណើរការមិនល្អក្នុងខែកក្កដា ឆ្នាំ២០២២ (ពិន្ទុធ្លាក់ពី៥,៣ ក្នុងខែមិថុនា មក ៤,៦) ដល់កម្រិតទាបជាងគេក្នុងឆ្នាំ២០២២។ ការធ្លាក់ចុះនេះបណ្តាលមកពីការថយចុះខ្លាំងនៃភាពអាចរកបានជាក់ស្តែងនៃទំនិញនៅលើទីផ្សារ និងតម្លៃទីផ្សារដែលអាចព្យាករបាន។ កម្រិតភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់ (ឧ.ទស្សនៈរបស់អ្នកលក់ទៅនឹងការបញ្ចេញស្តុក និងការបំពេញស្តុក) ក៏ធ្លាក់ទាបដូចគ្នាដែរ តែមានកម្រិតតិចជាងសមាសធាតុផ្សេងទៀត។ នៅចុងខែកក្កដា ឆ្នាំ ២០២២ មានប្រធានផ្សារ/អ្នកលក់ ១១,០% ដែលបានរាយការណ៍ពីការកើនឡើងនៃតម្លៃផ្គត់ផ្គង់ស្បៀង ដែលបានកើនឡើងខ្លាំងធៀបនឹងខែមុន (១,០%)។




*[1]សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ <u>លម្អិតពីវិធីសាស្រ្តរបស់សន្ទស្សន៍ដំណើរការផ្សារ</u>*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារទាំង៨៥ ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សារនៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣។

ចំនួនអតិថិជនទៅផ្សារនៅសប្តាហ៍ទី១ខែកក្កដា ឆ្នាំ២០២២ មានភាពល្អប្រសើរគួរឲ្យកត់សម្គាល់ មុនពេលធ្លាក់ចុះម្តងទៀតនៅសប្តាហ៍ទី៣នៃខែកក្កដា ឆ្នាំ២០២២ ទាបជាងគេបំផុតក្នុងរយៈពេលប្រាំពីរខែដំបូងឆ្នាំ២០២២។




បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

កំឡុងឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានហក់ឡើងខ្លាំងក្នុងខែឧសភា ហើយបន្ទាប់មកក៏មានស្ថេរភាព។ ក្នុងខែកក្កដា ឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន គឺ ១០៦.៦២៥ រៀល/ម្នាក់/ខែ (ប្រហែល ២៦,០ ដុល្លារ៖ +០,៥% ធៀបនឹងខែមុន -០,២% ធៀបនឹងឆ្នាំមុន) ហើយមានតម្លៃខ្ពស់ជាងបន្តិចនៅទីប្រជុំជន (២៦,៤ ដុល្លារ) បើធៀបនឹងជនបទ (២៥,៥ ដុល្លារ)។ ខណៈតម្លៃកញ្ចប់ស្បៀងអាហារបានថយចុះ ០,៣% នៅជនបទ វាបានកើនឡើង ០,៩% នៅទីប្រជុំជន បើធៀបនឹងខែមុន។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ជំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃខ្ពស់ជាងគេស្ថិតនៅផ្សារអូរឬស្សី រាជធានីភ្នំពេញ គឺ ១២៣.២២៥ រៀល/ម្នាក់/ខែ (ប្រហែល ៣០,១ ដុល្លារ) (១៦,០% ខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ)។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារដូនកែវ ខេត្តតាកែវ គឺ ៩១.៧៩៩ រៀល/ម្នាក់/ខែ (ប្រហែល ២២,៤ ដុល្លារ) (១៤,០% ទាបជាងតម្លៃមធ្យមថ្នាក់ជាតិ)។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់លើសពីតម្លៃមធ្យមថ្នាក់ជាតិមាននៅផ្សារនៅទីប្រជុំជន ដែលបង្ហាញពីបម្រែបម្រួលខ្ពស់ (៥% ឬលើសពីនេះ) ជាងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ បើធៀបនឹងផ្សារនៅជនបទ។

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែកក្កដា ឆ្នាំ២០២២)**




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ០,០% | ១០០,០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ៥០,០% | ៥០,០% |
| < ៥% ខ្ពស់ជាង | ៤១,៧% | ៥៨,៣% |
| < ៥% ទាបជាង | ៤៦,២% | ៥៣,៨% |
| ៥% ទៅ ១០% ទាបជាង | ៨៣,៣% | ១៦,៧% |
| ≥ ១០% ទាបជាង | ២៥,០% | ៧៥,០% |

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែកក្កដា ឆ្នាំ២០២២ តម្លៃស៊ុតទាបានកើនឡើង ៤,៣% ធៀបនឹងខែមុន ហើយឥឡូវគឺ ១៩,៦% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ តម្លៃអង្ករចម្រុះមានស្ថេរភាព (-0,២% ធៀបនឹងខែមុន និង -២,១% ធៀបឆ្នាំមុន)។ តម្លៃត្រកួនធ្លាក់ចុះ ៣,៤% ធៀបនឹងខែមុន តែនៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១០,៧%។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។

[2]ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្ដាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្ដាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ ។

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែកក្កដា ឆ្នាំ២០២២ តម្លៃសាច់ជ្រូក (-២,២% ធៀបនឹងខែមុន) និងប្រេងឆា (-១,៤% ធៀបនឹងខែមុន) បង្ហាញនិន្នាការថយចុះបន្តិច ចំណែកតម្លៃត្រីផ្ទក់បានកើនឡើង (+៦,១% ធៀបនឹងខែមុន)។ ប៉ុន្តែ តម្លៃប្រេងឆា ដែលភាគច្រើននាំចូលពីប្រទេសជិតខាង នៅមានតម្លៃ ៣១,៥% ថ្លៃជាងខែដូចគ្នាកាលពីឆ្នាំមុន។ តម្លៃត្រីផ្ទក់បានថយចុះ ២,៦% និងតម្លៃសាច់ជ្រូកបានថយចុះ ៨,០% ធៀបនឹងឆ្នាំមុន។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1] *ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅខែកក្កដា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយអង្ករចម្រុះ ស៊ុតទា ប្រេងឆា និងជំឡូងជ្វាពណ៌លឿង នៅជនបទ មានតម្លៃខ្ពស់ជាងបន្តិច។ ចំណែកតម្លៃលក់រាយត្រីផ្ទក់ សាច់ជ្រូក និងត្រកួន នៅទីប្រជុំជន មានតម្លៃខ្ពស់ជាង (តារាង១)។

ក្នុងខែកក្កដា ឆ្នាំ២០២២ តម្លៃមធ្យមលក់រាយស្បៀងអាហារសំខាន់ៗនៅទីប្រជុំជនមានបម្រែបម្រួលតិចតួច (≤ ៥,០%) ធៀបនឹងខែមុន។ ខណៈតម្លៃមធ្យមលក់រាយអង្ករចម្រុះ សាច់ជ្រូក និងប្រេងឆា នៅជនបទ ក៏បានបង្ហាញបម្រែបម្រួលតិចតួចធៀបនឹងខែមុន តម្លៃមធ្យមលក់រាយត្រីផ្ទក់ ស៊ុតទា ត្រកួន និងជំឡូងជ្វាពណ៌លឿង មានបម្រែបម្រួលគួរឲ្យកត់សម្គាល់នៅជនបទ។ ត្រីផ្ទក់ (+១២,៨% ធៀបនឹងខែមុន) ស៊ុតទា (+៥,៣% ធៀបនឹងខែមុន) ត្រកួន (-១៤,១% ធៀបនឹងខែមុន) និងជំឡូងជ្វាពណ៌លឿង (-១៣,១% ធៀបនឹងខែមុន) មានតម្លៃប្រែប្រួលគួរឲ្យកត់សម្គាល់ នៅជនបទ។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.១១០ | ២.១២៨ |
| ត្រីផ្ទក់ (រស់) (គក) | ១០.៣៤១ | ១០.២៨៤ |
| សាច់ជ្រូក (គក) | ១៩.៧៩៦ | ១៩.៤៨៤ |
| ស៊ុតទា (១០គ្រាប់) | ៦.១៤៤ | ៦.១៩៨ |
| ប្រេងឆា (៥លីត្រ) | ៣៤.៨៥៨ | ៣៤.៩៦១ |
| ត្រកួន (គក) | ២.៩១៤ | ២.៤២៧ |
| ជំឡូងជ្វាពណ៌លឿង | ២.២៧៧ | ២.៣៩០ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែមិថុនា ឆ្នាំ២០២២ និងខែកក្កដា ឆ្នាំ២០២២

**ជនបទ**




**ទីប្រជុំជន**




*សម្គាល់៖ ទិន្នន័យនេះទទួលបានពីផ្សារចំនួន៨៥។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

រដូវវស្សាឆ្នាំ២០២២ បានចាប់ផ្ដើមនៅដើមខែឧសភា ហើយក៏មានភាពសើមជាងមធ្យមភាគរយៈច្រើនឆ្នាំ។ ខណៈដែលបរិមាណទឹកភ្លៀងបានថយចុះបង្គួរនៅក្នុងខែមិថុនា ធៀបនឹងមធ្យមច្រើនឆ្នាំ (ក្រាហ្វិកខាងឆ្វេង) បរិមាណទឹកភ្លៀងជាមធ្យមថ្នាក់ជាតិក្នុងខែកក្កដា ឆ្នាំ២០២២ ខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំគួរឲ្យកត់សម្គាល់។ បរិមាណទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបក្នុងរយៈពេល៣ខែចុងក្រោយ (ឧសភា-កក្កដា ឆ្នាំ២០២២) បានបង្ហាញថាប្រទេសកម្ពុជាកំពុងមានស្ថានភាពសើមជាងធម្មតា។ នេះទំនងជាផ្ដល់លក្ខខណ្ឌអំណោយផល និងទឹកគ្រប់គ្រាន់សម្រាប់ការដាំដុះដំណាំស្រូវដំណាក់កាលដំបូង។ ប៉ុន្តែ នេះក៏បង្ហាញពីទឹកជំនន់រហ័សនៅក្នុងបណ្ដាខេត្តមួយចំនួន ដែលអាចប៉ះពាល់ដល់ដំណាំស្រូវដែរ។

ផ្អែកតាមសន្ទស្សន៍ទឹកភ្លៀងស្តង់ដារ (SPI) ចាប់ពីខែមេសាដល់ខែមិថុនា ឆ្នាំ២០២២ (ទិន្នន័យ SPI សម្រាប់ខែឧសភា-ខែកក្កដា មិនទាន់មាននៅឡើយទេ) ខេត្តភាគច្រើនមានស្ថានភាពពី "ធម្មតា" ទៅ "សើមខ្លាំងណាស់" លើកលែងខេត្តនៅភាគខាងលិចប្រទេស រួមមាន ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងផ្នែកខ្លះនៃខេត្តកំពង់ឆ្នាំង ខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលមានស្ថានភាពស្ងួតជាងធម្មតាពីកម្រិត "តិច" ទៅ "ខ្លាំង" (ផែនទីខាងក្រោម)។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែកក្កដា ឆ្នាំ២០២២) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា–កុម្ភៈ | មីនា–មេសា(១) | មេសា(២)–ឧសភា | ឧសភា(៣)–មិថុនា | កក្កដា–តុលា | វិច្ឆិកា–ធ្នូ |
|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ប្រមូលផល | | | | រៀបចំដី និង សាបព្រោះ |
| ស្រូវរដូវវស្សារ | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | | ស្ទូង / ដាំដុះ | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## សន្ទស្សន៍ទឹកភ្លៀងស្តង់ដាររយៈពេល៣ខែ (SPI-3)
## ខែមេសា - ខែមិថុនា ឆ្នាំ២០២២



# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

រុក្ខជាតិមានស្ថានភាពដូចទៅនឹងរបាយទឹកភ្លៀងក្នុងរយៈពេល៣ខែចុងក្រោយ។ ក្នុងខែកក្កដា ឆ្នាំ២០២២ ស្ថានភាពរុក្ខជាតិទំនងជាមានភាពល្អប្រសើរ ដោយសារតែមានទឹកភ្លៀងគ្រប់គ្រាន់ បើធៀបនឹងខែមុន។ នៅទូទាំងប្រទេសមានស្ថានភាពរុក្ខជាតិល្អជាងធម្មតា ពិសេសតាមបណ្ដាខេត្តក្នុងតំបន់ទំនាបកណ្ដាល (ឧ. ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តតាកែវ) ជាតំបន់ដាំដុះស្រូវរដូវវស្សាដ៏ធំ (ផែនទីខាងស្ដាំ)។

ផ្អែកតាមក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) គិតត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ ផ្ទៃដីដាំដុះស្រូវរដូវវស្សាសម្រេចបាន ២,៣ លាន ហិកតា ៩០% នៃផែនការប្រចាំឆ្នាំ។ ប៉ុន្តែ ការដាំដុះមានល្បឿនយឺតជាងកាលពីឆ្នាំមុន ដោយសារតែមានភ្លៀងធ្លាក់ច្រើននៅដើមរដូវវស្សា។ បន្ថែមលើនេះទៀត ភ្លៀងធ្លាក់ច្រើនក្នុងពាក់កណ្ដាលខែកក្កដាបានបង្កឲ្យមានទឹកជំនន់នៅក្នុងតំបន់មួយចំនួន និងប៉ះពាល់ដល់ការដាំដុះស្រូវរដូវវស្សា។

កត្តាផ្សេងទៀត ដែលទំនងធ្វើឲ្យផ្ទៃដីដាំដុះថយចុះទំនងជាការកើនឡើងតម្លៃធាតុចូលកសិកម្ម ដូចជាប្រេងឥន្ធនៈ និងជី ដែលបានកើនឡើងតាំងពីចាប់ផ្ដើមវិបត្តិអ៊ុយក្រែន។ ខណៈដែលកម្ពុជាប្រើប្រាស់ជីកសិកម្មក្នុងបរិមាណទាប (៤២,៧ គ.ក/ហិកតា) ជាងប្រទេសជនទៃក្នុងតំបន់ កម្ពុជាពឹងផ្អែកខ្លាំងលើការនាំចូលជីកសិកម្ម (នីត្រូសែន ផូស្វ័រ និងប៉ូតាស្យូម) ដែលភាគច្រើនមានប្រភពមកពីប្រទេសវៀតណាម (៥៣,០%) ថៃ (៣៩,៤%) និងចិន (៩,៨%)។ តម្លៃជីសកលបានមានស្ថេរភាព ឬធ្លាក់ថ្លៃបន្តិចក្នុងរយៈពេលប្រាំខែ ចាប់តាំងពីប្រទេសរុស្ស៊ីឈ្លានពានប្រទេសអ៊ុយក្រែន ប៉ុន្តែនៅតែមានតម្លៃខ្ពស់ជាងកាលពីឆ្នាំ២០២១ខ្លាំង។ បន្ថែមលើក្ដីបារម្ភពីការផ្គត់ផ្គង់ ប្រទេសមួយចំនួន ដូចជា ប្រទេសចិន រុស្ស៊ី អ៊ុយក្រែន និងវៀតណាម កំពុងរឹតបន្តឹងការនាំចេញ ឬប្រើវិធានការផ្ដល់អាជ្ញាប័ណ្ណសម្រាប់ជីកសិកម្ម ដើម្បីធានាបាននូវភាពអាចរកបានក្នុងស្រុក។ គិតត្រឹមខែកក្កដា ប្រទេសចំនួន១៨ បានហាមឃាត់ការនាំចេញស្បៀងអាហារចំនួន ២៧ ហើយប្រទេសចំនួន៧ បានកំណត់វិធានការរឹតត្បិតការនាំចេញចំនួន១១។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)**
**ក្នុងខែកក្កដា ឆ្នាំ២០២២**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*

*ចំណាំ៖ ការបកស្រាយពីសុខភាពរុក្ខជាតិមានកម្រិតដោយសារការគ្របដណ្ដប់ដោយពពក*

# ពាណិជ្ជកម្ម

**ស្ថិតិសរុបនៃពាណិជ្ជកម្មនៅតែបង្ហាញវឌ្ឍនភាពជាវិជ្ជមាន។** ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ១៣,៧៧ ពាន់លាន ដុល្លារ ក្នុងរយៈពេលប្រាំពីរខែដំបូងឆ្នាំ២០២២ ៣០,៧% ខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុន។ ចន្លោះខែមករា និងខែកក្កដា ឆ្នាំ២០២២ ការនាំចេញអង្ករមានចំនួន ៣៥០.៩០២ តោន (មានតម្លៃប្រមាណ ២១៨,១៧ លាន ដុល្លារ) បានកើនឡើង ១៣,២៥% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន ហើយប្រទេសចិននៅតែជាប្រទេសស្រូបយកការនាំចេញអង្ករពីកម្ពុជាច្រើនជាងគេ (៤៨%) បន្ទាប់មកគឺសហភាពអឺរ៉ុប (៣២%)។ បន្ថែមលើការនាំចេញអង្ករ ការនាំចេញស្រូវមានចំនួន ១,៩៥ លាន តោន (មានតម្លៃប្រមាណ ៤៨៧,២៤ លាន ដុល្លារ) ក្នុងរយៈពេលដូចគ្នា។

**កម្ពុជាបាននាំចូលជាផ្លូវការ**នូវធញ្ញជាតិសរុបចំនួន ៤០,៤ លាន ដុល្លារ (-២៨,៥% ធៀបឆ្នាំមុន) សាច់ និងសំណល់សាច់ (គ្រឿងក្នុង) ដែលអាចបរិភោគបានចំនួន ៣៩,៤ លាន ដុល្លារ (+១៦១,៦% ធៀបឆ្នាំមុន) បន្លែដែលអាចបរិភោគបាន និងឬស/មើមចំនួន ៥,១ លាន ដុល្លារ (+១០,៣% ធៀបឆ្នាំមុន) និងខ្លាញ់សត្វ ប្រេងរុក្ខជាតិចំនួន ១២,៥ លាន ដុល្លារ (+៥,៧%) ក្នុងរយៈពេលប្រាំពីរខែដំបូងឆ្នាំ២០២២។

**ឆ្លើយតបទៅនឹងផលប៉ះពាល់ផ្នូននៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន** បញ្ហាខ្សែច្រវាក់ផ្គត់ផ្គង់សកលកំពុងបន្ត ផលវិបាកនៃកូវីដ-១៩ និងព្រឹត្តិការណ៍ប្រែប្រួលធាតុអាកាសក្នុងប្រទេសផលិតស្រូវសាឡីលើសកលលោក ប្រទេសមួយចំនួននៅរក្សាការហាមឃាត់/រិតត្បិតការនាំចេញស្បៀងអាហារដដែរ។

**បច្ចុប្បន្ន ប្រទេសកម្ពុជាមិនទាន់មានក្តីបារម្ភពីការផ្គត់ផ្គង់អង្ករនៅឡើយទេ។** ម្យ៉ាងទៀត តម្លៃអង្ករនាំចេញរបស់កម្ពុជាបន្តកើនឡើង ដោយសារតែប្រទេសផលិតស្រូវសាឡីមួយចំនួន បានហាមឃាត់ការនាំចេញដើម្បីធានាសុវត្ថិភាពស្បៀងក្នុងប្រទេសរបស់ខ្លួន។ តម្លៃអង្ករនាំចេញជាមធ្យមក្នុងរយៈពេលប្រាំមួយខែដំបូងឆ្នាំ២០២២ កើនដល់ ៨៥,៥ សេន ដុល្លារ ០,៩៤% ខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុន។

**ចំណូលសរុបនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា**មានចំនួនប្រមាណ ៩៧០ លាន ដុល្លារ (៥៧ លាន ដុល្លារសម្រាប់វិស័យស្បៀងអាហារ) ហើយត្រូវបានព្យាករថានឹងកើនដល់ ១.១១៧ លាន ដុល្លារនៅឆ្នាំ២០២២)។

## សមត្ថភាពពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ គិតត្រឹមខែកក្កដា ឆ្នាំ២០២២




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ រដ្ឋាភិបាលបានសម្រេចបន្តអនុវត្តកម្មវិធីរហូតដល់ចុងខែកញ្ញា ឆ្នាំ២០២២។ គ្រួសារក្រីក្រប្រមាណ ៦៨៨.៨៩១ គ្រួសារ (ប្រមាណ ២,៧ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៧៩៤,៦ លាន ដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២។

ការវាយតម្លៃបច្ច័យដែលបានគាំទ្រដោយ UNDP បានបង្ហាញថា ក្នុងឆ្នាំ២០២១ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្របានរួមចំណែក ០,៤% ដល់កំណើន GDP កាត់បន្ថយអត្រាភាពគ្មានការងារធ្វើបាន ០,៦២% កាត់បន្ថយអត្រានៃភាពក្រីក្របាន ៣,៤%។ ការវាយតម្លៃបានបង្ហាញថា គ្រួសារក្រីក្រដែលបានទទួលប្រាក់ឧបត្ថម្ភ បានចំណាយ ៩២% នៃប្រាក់ឧបត្ថម្ភប្រចាំខែទៅលើស្បៀងអាហារ។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

នៅចុងខែកក្កដា ឆ្នាំ២០២២ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមហ៊ុនឯកជនបានចុះហត្ថលេខាលើកម្ចីចំនួន ១៥ លាន ដុល្លារ ក្នុងការជម្រុញខ្សែច្រវាក់ផ្គត់ផ្គង់ចំណីសត្វ ដើម្បីកាត់បន្ថយលំហូរចេញនៃវត្ថុធាតុដើមកសិកម្មពីក្នុងប្រទេស ក៏ដូចជាបង្កើនផលិតកម្មចំណីសត្វក្នុងស្រុកផងដែរ ដោយសារបច្ចុប្បន្នផលិតកម្មចំណីសត្វអាចផ្គត់ផ្គង់តម្រូវការក្នុងស្រុកបានតែ ៥៥% ប៉ុណ្ណោះ។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ប្រទេសកម្ពុជា និងថៃបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាលើវិស័យភស្តុភារ (logistics) ដើម្បីកាត់បន្ថយតម្លៃ និងពេលវេលាដឹកជញ្ជូនទំនិញឆ្លងព្រំដែន ដែលអាចទម្លាក់តម្លៃទំនិញនៅលើទីផ្សារផងដែរ។

ធនាគារជាតិនៃកម្ពុជា (NBC) រំពឹងថាការអនុវត្តគោលនយោបាយរូបិយវត្ថុនឹងអាចរក្សាស្ថេរភាពអត្រាប្តូរប្រាក់ដុល្លារ/រៀល នៅក្នុងឆមាសទីពីរនៃឆ្នាំ២០២២ ដែលអាចជួយជម្រុញកម្លាំងទិញ និងកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងអតិផរណា។

ខណៈដែលតម្លៃអគ្គិសនីនៅក្នុងប្រទេសមួយចំនួនបានឡើងថ្លៃទ្វេដង តម្លៃអគ្គិសនីនៅកម្ពុជានៅតែមានស្ថេរភាព ដោយសារតែរដ្ឋាភិបាលបានឧបត្ថម្ភធនជាង ១០០ លាន ដុល្លារ ទៅឲ្យអគ្គិសនីកម្ពុជា ដែលជាក្រុមហ៊ុនរបស់រដ្ឋ ដើម្បីរក្សាស្ថេរភាពតម្លៃអគ្គិសនី។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៥,១៣ លាននាក់ (៥០,៩% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៣,៣% (៩៤,៥៦% នៃប្រជាជនសរុប)។




*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២*

**ការចាក់វ៉ាក់សាំងកូវីដ-១៩**




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី១ ខែសីហា ឆ្នាំ២០២២*

# វិធីសាស្រ្ត និងទីតាំងផ្សារ

## ទីផ្សារដែលបានប្រមូលទិន្នន័យ

World Food Programme




កម្មវិធីស្បៀងអាហារពិភពលោកចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទតាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានារៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ ក្នុងទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។

ក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ កម្មវិធីស្បៀងអាហារពិភពលោក បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្រប់ដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក កម្មវិធីស្បៀងអាហារពិភពលោកបានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។


**ការិយាល័យទីផ្សារកសិកម្ម**

នាយកដ្ឋានផែនការនិងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**

ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែ (កក្កដា ២០២២) | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| 1.1. អង្ករចម្រុះ/ Mixed Rice | Riels/Kg | 2,118 | → -0.2% | → 2.6% | → -2.1% |
| 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | Riels/Kg | 10,320 | ↑ 6.1% | → 2.8% | → -2.6% |
| 2.2. ត្រីប្រា(រស់)/ Trey Pra (Live) | Riels/Kg | 7,058 | ↑ 6.6% | ↑ 6.6% | → 0.5% |
| 2.3. ត្រីអណ្តែង(រស់)/ Cat fish (Live) | Riels/Kg | 9,075 | ↑ 10.0% | ↑ 23.6% | ↑ 17.4% |
| 2.4. ត្រីផ្ទក់ងៀត/ Dried snake fish | Riels/Kg | 25,428 | → 4.0% | → 1.3% | → -0.4% |
| 3.1. សាច់ជ្រូកពងជាន់/ 3-layer pork/Pork with fat | Riels/Kg | 19,657 | → -2.2% | → -3.9% | ↓ -8.0% |
| 4.1. ស៊ុតទា/Duck egg (Riels/10 eggs) | Riels/10 eggs | 6,168 | → 4.3% | ↑ 9.2% | ↑ 19.6% |
| 4.2. ស៊ុតទាប្រៃ/Salty/Fermented duck egg | Riels/10 eggs | 7,333 | → 0.1% | ↑ 5.4% | ↑ 16.8% |
| 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | Riels/ 5 litre | 34,900 | → -1.4% | → 0.5% | ↑ 31.5% |
| 6.1. អំបិលម៉ត់អ៊ីយូត/ Iodized salt | Riels/Kg | 1,209 | → 1.3% | → -2.1% | → 3.4% |
| 7.1. សណ្តែកដី/ Ground Nut* | Riels/Kg | 8,373 | → -2.3% | ↓ -12.2% | ↓ -19.7% |
| 8.1. ត្រកួន/ Morning glory | Riels/Kg | 2,721 | → -3.4% | ↓ -9.4% | ↑ 10.7% |
| 8.2. ការ៉ុត/ Carrot* | Riels/Kg | 3,518 | ↓ -13.8% | → -3.7% | ↑ 5.4% |
| 8.3. ស្លឹកបាស/ Ivy gourd leave* | Riels/Kg | 4,487 | ↓ -15.0% | → 1.1% | ↑ 13.2% |
| 8.4. ស្លឹកម្រុំ/ Moringa leaves* | Riels/Kg | 4,723 | ↓ -14.4% | ↓ -10.9% | ↑ 42.2% |
| 8.5. ស្ពៃក្រញាញ់/ Chinese spinach* | Riels/Kg | 4,221 | ↓ -5.7% | → 0.5% | ↑ 19.8% |
| 8.6. ស្ពៃតឿ/ Pak Choi* | Riels/Kg | 4,240 | → -0.2% | ↑ 9.2% | ↑ 17.4% |
| 8.7. ស្ពៃចង្កឹះ/Chinese flowering cabbage | Riels/Kg | 3,706 | → 5.0% | → 3.2% | ↑ 38.6% |
| 8.8. ស្ពៃខៀវ/Mustard Greens* | Riels/Kg | 3,654 | → -3.3% | ↑ 14.0% | ↑ 17.2% |
| 8.9. ផ្ទីដូង/ Amaranthus* | Riels/Kg | 4,021 | → -3.5% | ↑ 11.6% | ↑ 21.2% |
| 8.10. ស្លឹកងប់/ Ngob leaves* | Riels/Kg | 5,754 | → -3.8% | ↓ -7.4% | → 3.3% |
| 8.11. ត្រួយល្ពៅ/ Pumpkin leaves* | Riels/Kg | 4,512 | ↓ -18.2% | ↓ -6.7% | ↓ -13.0% |
| 8.12. ផ្លែល្ពៅ/ Pumpkin fruit* | Riels/Kg | 2,401 | → -3.7% | ↑ 5.9% | ↑ 18.9% |
| 8.13. ឃ្លោក/ Bottle gourd* | Riels/Kg | 2,442 | ↑ 42.5% | ↑ 46.5% | ↑ 22.1% |
| 8.14. ត្រឡាច/ Wax gourd | Riels/Kg | 2,501 | → -3.9% | ↑ 17.7% | ↓ -10.5% |
| 8.15. ត្រប់វែង/ Long eggplants | Riels/Kg | 3,153 | → -0.6% | ↑ 17.7% | ↑ 20.3% |
| 8.16. ត្រប់ស្រួយ/ Round eggplants* | Riels/Kg | 3,015 | → -4.6% | → 2.2% | ↑ 17.4% |
| 8.17. ប៉េងប៉ោះ/ Tomatoes* | Riels/Kg | 4,168 | ↑ 18.2% | ↑ 24.0% | ↑ 7.3% |
| 8.18.ននោងមូល/ Spong gourd | Riels/Kg | 3,159 | → 4.8% | ↑ 33.1% | ↑ 25.2% |
| 8.19. ននោងជ្រុង/ Ridge Gourd* | Riels/Kg | 3,173 | → 0.5% | ↑ 41.3% | ↑ 11.1% |
| 8.20. ល្ហុងខ្ចី/ Green papaya* | Riels/Kg | 1,335 | ↓ -13.6% | ↓ -7.8% | ↓ -10.1% |
| 8.21. សណ្តែកគួរ/ Long bean | Riels/Kg | 3,978 | ↓ -21.5% | ↑ 25.5% | → 3.4% |
| 8.22. ត្រយូងចេក/ Banana flower* | Riels/Kg | 1,999 | ↓ -18.5% | ↓ -5.3% | ↓ -16.3% |
| 8.23. ផ្កាខាត់ណា/ Cauliflower* | Riels/Kg | 7,629 | → 2.9% | ↑ 21.1% | → -0.8% |
| 8.24. ដើមខាត់ណា/ Chinese Kale* | Riels/Kg | 5,700 | ↑ 17.5% | ↑ 20.1% | ↑ 7.9% |
| 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes* | Riels/Kg | 2,323 | → 2.7% | → -4.5% | ↑ 9.6% |

# ឧបសម្ព័ន្ធទី១

## បម្រែបម្រួលតម្លៃលក់រាយ

## (ខែកក្កដា ឆ្នាំ២០២២)

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%

→ ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%

↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

* តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែ (កក្កដា ២០២២) | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| 1.1. អង្ករចម្រុះ/ Mixed Rice | Riels/Kg | 1,957 | → -0.1% | → 2.0% | → -4.0% |
| 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | Riels/Kg | 9,380 | ↑ 7.2% | → 2.9% | → -2.8% |
| 2.2. ត្រីប្រា(រស់)/ Trey Pra (Live) | Riels/Kg | 6,231 | ↑ 7.8% | → 3.3% | → -1.4% |
| 2.3. ត្រីអណ្ដែង(រស់)/ Cat fish (Live) | Riels/Kg | 8,191 | ↑ 9.6% | ↑ 21.5% | ↑ 19.1% |
| 2.4. ត្រីផ្ទក់ងៀត/ Dried snake fish | Riels/Kg | 23,327 | → 3.7% | → 2.4% | → -2.9% |
| 3.1. សាច់ជ្រូកពងជាន់/ 3-layer pork/Pork with fat | Riels/Kg | 18,109 | → -2.0% | → -4.4% | ↓ -8.9% |
| 4.1. ស៊ុតទា/Duck egg (Riels/10 eggs) | Riels/10 eggs | 5,746 | → 4.1% | ↑ 8.8% | ↑ 19.6% |
| 4.2. ស៊ុតទាប្រៃ/Salty/Fermented duck egg | Riels/10 eggs | 6,783 | → 0.1% | ↑ 5.1% | ↑ 16.0% |
| 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | Riels/ 5 litre | 33,943 | → 0.8% | → 0.6% | ↑ 32.1% |
| 6.1. អំបិលម៉ត់អ៊ីយូត/ Iodized salt | Riels/Kg | 987 | → -0.5% | → -4.8% | → 1.6% |
| 7.1. សណ្ដែកដី/ Ground Nut* | Riels/Kg | 7,831 | → -0.9% | ↓ -9.5% | ↓ -16.6% |
| 8.1. ត្រកួន/ Morning glory | Riels/Kg | 2,126 | ↓ -8.0% | ↓ -17.5% | ↑ 5.2% |
| 8.2. ការ៉ុត/ Carrot* | Riels/Kg | 2,891 | ↓ -15.2% | ↓ -6.9% | → 2.8% |
| 8.3. ស្លឹកបាស/ Ivy gourd leave* | Riels/Kg | 3,483 | ↓ -15.5% | → -1.7% | ↑ 8.0% |
| 8.4. ស្លឹកម្រុំ/ Moringa leaves* | Riels/Kg | 3,724 | ↓ -18.7% | ↓ -23.2% | ↑ 28.7% |
| 8.5. ស្ពៃក្រញាញ់/ Chinese spinach* | Riels/Kg | 3,499 | ↓ -6.6% | → -1.0% | ↑ 20.1% |
| 8.6. ស្ពៃតឿ/ Pak Choi* | Riels/Kg | 3,589 | → 0.8% | ↑ 8.5% | ↑ 18.8% |
| 8.7. ស្ពៃចង្កឹះ/Chinese flowering cabbage | Riels/Kg | 3,058 | ↑ 5.1% | → 2.0% | ↑ 38.1% |
| 8.8. ស្ពៃខៀវ/Mustard Greens* | Riels/Kg | 3,035 | → -1.9% | ↑ 15.8% | ↑ 19.9% |
| 8.9. ផ្ទីដូង/ Amaranthus* | Riels/Kg | 3,131 | → -4.8% | ↑ 9.6% | ↑ 28.3% |
| 8.10. ស្លឹកងប់/ Ngob leaves* | Riels/Kg | 4,513 | ↓ -9.7% | ↓ -8.4% | → 0.3% |
| 8.11. ត្រួយល្ពៅ/ Pumpkin leaves* | Riels/Kg | 3,481 | ↓ -25.5% | ↓ -21.2% | ↓ -18.1% |
| 8.12. ផ្លែល្ពៅ/ Pumpkin fruit* | Riels/Kg | 1,826 | ↓ -6.0% | → 1.6% | ↑ 18.7% |
| 8.13. ឃ្លោក/ Bottle gourd* | Riels/Kg | 1,888 | ↑ 39.4% | ↑ 41.6% | ↑ 18.0% |
| 8.14. ត្រឡាច/ Wax gourd | Riels/Kg | 1,982 | → -4.5% | ↑ 16.9% | ↓ -15.4% |
| 8.15. ត្រប់វែង/ Long eggplants | Riels/Kg | 2,495 | → -2.6% | ↑ 13.4% | ↑ 13.2% |
| 8.16. ត្រប់ស្រួយ/ Round eggplants* | Riels/Kg | 2,338 | ↓ -7.3% | ↓ -6.1% | ↑ 8.7% |
| 8.17. ប៉េងប៉ោះ/ Tomatoes* | Riels/Kg | 3,519 | ↑ 23.0% | ↑ 22.7% | ↑ 7.6% |
| 8.18. នននោងមូល/ Spong gourd | Riels/Kg | 2,447 | → 0.9% | ↑ 23.3% | ↑ 17.9% |
| 8.19. នននោងជ្រុង/ Ridge Gourd* | Riels/Kg | 2,555 | → 3.5% | ↑ 34.9% | ↑ 10.1% |
| 8.20. ល្ហុងខ្ចី/ Green papaya* | Riels/Kg | 966 | ↓ -16.4% | ↓ -17.6% | ↓ -16.3% |
| 8.21. សណ្ដែកគួរ/ Long bean | Riels/Kg | 3,245 | ↓ -24.5% | ↑ 21.3% | → -1.0% |
| 8.22. ត្រយូងចេក/ Banana flower* | Riels/Kg | 1,584 | ↓ -21.4% | ↓ -13.1% | ↓ -19.1% |
| 8.23. ផ្កាខាត់ណា/ Cauliflower* | Riels/Kg | 6,637 | → 3.0% | ↑ 14.6% | → -1.3% |
| 8.24. ដើមខាត់ណា/ Chinese Kale* | Riels/Kg | 4,868 | ↑ 18.4% | ↑ 16.8% | → 4.9% |
| 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes* | Riels/Kg | 1,842 | → 2.5% | ↓ -11.8% | ↑ 8.5% |

# ឧបសម្ព័ន្ធទី២

## បម្រែបម្រួលតម្លៃលក់ដុំ

## (ខែកក្កដា ឆ្នាំ២០២២)

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

* តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍ គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,599 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.3 | 28,574 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 19.7 | 24,338 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 9.9 | 3,556 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 7.7 | 2,994 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 2.7 | 19,179 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.3 | 1,385 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **106,625** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ ខែកក្កដា ឆ្នាំ២០២២ WFP ប្រចាំប្រទេសកម្ពុជា។*